N-31
23-8-02

ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១២-៨-២០០២ - ព្រះរាជក្រឹត្យ នស/រកត/០៨-០២/២៤៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក ប្រេតតុន ស្ការ៉ូនី (BRETTON G SCIARONI) សញ្ជាតិដើមអាមេរិក កើតនៅក្រុងឡូសអានហ្ស៊ីឡែស រដ្ឋកាលីហ្វូនា សហរដ្ឋអាមេរិក ២២៨៦

II-រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១៦-៨-២០០២ - អនុក្រឹត្យលេខ ៨៥ អនក្រ.បក ស្តីពីការបង្កើនប្រាក់ម្ហូបអាហារ ជូនកងយោធពលខេមរភូមិន្ទ ២២៨៧

១៩-៨-២០០២ - អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីការកែសំរួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ២២៨៩

២១-៨-២០០២ - អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ២២៩៥

២១-៨-២០០២ - អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពី ភារកិច្ចនិងបេសកកម្មនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ២៣០០

១៥-៨-២០០២ - អនុក្រឹត្យលេខ ៤០៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ២៣០៣

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣០៤

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣០៥

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣០៦

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣០៧

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣០៨

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភណ្ឌ ២៣០៩

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣១០

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៣១១

១៩-៨-២០០២ - អនុក្រឹត្យលេខ ៤១៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ២៣៤៥

២១-៨-២០០២ - អនុក្រឹត្យលេខ ៤១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៣៤៦

២១-៨-២០០២ - អនុក្រឹត្យលេខ ៤១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៣៤៨

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៦-៨-២០០២ -ប្រកាសលេខ ៥៣៧ សហវ ឧ.ហ ស្តីពីការដកហូតអាជ្ញាប័ណ្ណឆ្នោត ជាបណ្តោះអាសន្ន របស់ក្រុមហ៊ុនឆ្នោត រ៉ូយ៉ាល់ហ្គ្លូប ២៣៤៩

២០-៨-២០០២ -ប្រកាសលេខ ៥៤១ សហវ ឧ.ហ ស្តីពីការបង្កើតក្រុមប្រតិបត្តិប្រចាំនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុ ២៣៥១

២០-៨-២០០២ -ប្រកាសលេខ ៥៤៤ សហវ ឧ.ហ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រង ក្រុមហ៊ុន សាជីវកម្មឆ្នោតឡូតូ និងការលេងភ្នាល់គ្រប់ប្រភេទ(មិនមែនកាស៊ីណូ) ២៣៥៣

២០-៨-២០០២ -ប្រកាសអន្តរក្រសួងលេខ ៥៤៥ សហវ ស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន នៅក្រសួងអប់រំ យុវជន និង កីឡា ២៣៥៥

២០-៨-២០០០ -ប្រកាសអន្តរក្រសួងលេខ ៥៤៦ សហវ ស្តីពីការបង្កើត និងតែងតាំងភ្នាក់ងារបើកផ្តល់សំរាប់បើកបៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធមិជូនមន្ត្រីរាជការ នៅក្រសួងអប់រំ យុវជន និង កីឡា ២៣៥៧

ព្រះរាជក្រឹត្យ

យើង

នស / រកត / ០៨០២/២៤៤

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០២

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ប្រេតតុន ស្ការ៉ូនី** (BRETTON G SCIARONI) សញ្ជាតិដើមអាមេរិក កើតថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៥១ នៅក្រុងឡូសអានហ្ស៊ីឡេស រដ្ឋកាលីហ្វូនា សហរដ្ឋអាមេរិក ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

លេខ: ១៧៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៧ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សរទី តាន

ការស.៧.០៨.០០២៥៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការបង្កើនប្រាក់ម្ហូបអាហារ

ជូនកងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពីបៀវត្សរ៍មូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍ របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការកែសំរួលប្រព័ន្ធបៀវត្សរ៍របស់កងយោធពលខេមរភូមិន្ទ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១.-

ជាបណ្ដោះអាសន្ន ត្រូវបានបង្កើនប្រាក់ម្ហូបដល់កងយោធពលខេមរភូមិន្ទគ្រប់ប្រភេទទ័ព ចំនួន ៦០០៛០០ (ប្រាំមួយរយរៀលគត់) ក្នុងម្នាក់មួយថ្ងៃ លើចំនួនប្រាក់ដែលកំពុងអនុវត្តបច្ចុប្បន្ន ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី
ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី
សមាជិកអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សុខ អាន

<u>**កន្លែងទទួល**</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

4r

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៨៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

សំ រេ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះមានគោលបំណងកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន ទៅលើខ្លឹមសារ និងរចនាសម្ព័ន្ធ ដែលចែងក្នុងអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា ២ : ត្រូវបានបង្កើតបំពេញបន្ថែមនាយកដ្ឋានចំនួន ៤ ដូចខាងក្រោម ដែលស្ថិតចំណុះក្រសួងប្រៃសណិយ៍ និងទូរគមនាគមន៍ :

- នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ
- នាយកដ្ឋានប្រៃសណីយ៍
- នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
- នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ

មាត្រា ៣ : ត្រូវបានកែសំរួលតួនាទីភារកិច្ច និងឈ្មោះនាយកដ្ឋានរដ្ឋបាលបណ្តុះបណ្តាល និងហិរញ្ញវត្ថុ ទៅជានាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល វិញ ដោយកាត់យកការងារហិរញ្ញវត្ថុ ដែលមានចែងក្នុងចំណុច " ឃ" និង " ខ" នៃមាត្រា ៧ ជំពូក ៥ នៃ អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ យកមកដាក់បញ្ចូលក្នុងតួនាទីភារកិច្ច របស់នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នៃអនុក្រឹត្យនេះ វិញ ។

ជំពូកទី ២

អំពីរចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា ៤ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និងនាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប (០១រូប) និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

40

មាត្រា ៥ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និង នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ មានការិយាល័យ ចំណុះមួយចំនួនតាមការចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យចំណុះ បណ្ដានាយកដ្ឋាន ដូចមានចែងក្នុងមាត្រា ២ ត្រូវកំណត់ដោយ ប្រកាសរបស់ រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

ជំពូកទី ៣

អំពីភារកិច្ច

មាត្រា ៦ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ មានភារកិច្ច ដូចខាងក្រោម :

- សិក្សា និងកសាងគំរោងផែនការអភិវឌ្ឍន៍លើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍ រយៈពេលមធ្យម និង រយៈពេលវែង
- កសាងគំរោងផែនការចំណូល-ចំណាយហិរញ្ញវត្ថុ
- គ្រប់គ្រងការងារប្រមូលចំណូលអាជីវកម្ម-សេវាកម្ម លើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍
- គ្រប់គ្រងបេឡាសាច់ប្រាក់ជារៀល និងរូបិយប័ណ្ណតាមច្បាប់ហិរញ្ញវត្ថុជាធរមាន
- គ្រប់គ្រងសំភារៈ និងបរិក្ខារបស់ក្រសួង
- គ្រប់គ្រងការងារលទ្ធកម្មសាធារណៈ
- គ្រប់គ្រងការងារវិក័យប័ត្រ
- គ្រប់គ្រងការងារសំណង់ វិស្វកម្ម
- អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៧ : នាយកដ្ឋានប្រៃសណីយ៍ មានភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រងនិងធ្វើអាជីវកម្ម លើបណ្ដាសេវាប្រៃសណីយ៍ ដែលបានកំណត់តាមច្បាប់ស្ដីពីវិស័យប្រៃសណីយ៍
- ទទួលសិទ្ធក្នុងការបោះពុម្ពតែមប្រៃសណីយ៍ តែមប្រើពិន័យ និងរាល់លិខិតស្នាមសំរាប់វិស័យប្រៃសណីយ៍
- គ្រប់គ្រង និង រៀបចំឯកសារផែនការអភិវឌ្ឍន៍ សំរាប់រយៈពេលមធ្យម និង រយៈពេលវែង នៃវិស័យ ប្រៃសណីយ៍ទូទាំងប្រទេស
- គ្រប់គ្រងចំណូលអាជីវកម្ម-សេវាកម្មប្រៃសណីយ៍គ្រប់ប្រភេទ
- កសាងគំរោងផែនការចំណូល-ចំណាយថវិកា តាមតំណាក់កាលនិមួយ ៗ
- កសាងគំរោងផែនការសហប្រតិបត្តិការជាមួយបរទេស ស្ដីពីការទំនាក់ទំនងអាជីវកម្ម-សេវាកម្មប្រៃសណីយ៍
- អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៨ : នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងបណ្តាញទូរគមនាគមន៍ និងធ្វើសេវាកម្មមាត់ច្រកអន្តរជាតិ

-ធ្វើគំរោងអភិវឌ្ឍន៍បណ្តាញទូរគមនាគមន៍អន្តរជាតិ

-គ្រប់គ្រងការបញ្ជូន និងទទួលរូបភាពទៅអន្តរជាតិ

-គ្រប់គ្រងការជួលជាវបរិបថអន្តរជាតិ

-គ្រប់គ្រងប្រព័ន្ធវិទ្យុឆ្នេរសមុទ្រ តាមដងទន្លេ

-សំរបសំរួលបណ្តាញទូរគមនាគមន៍ ពីមាត់ច្រកអន្តរជាតិ ទៅប្រទេសជាដៃគូទាំងអស់លើពិភពលោក

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៩ : នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងមជ្ឈមណ្ឌលទូរស័ព្ទ របស់ក្រសួងដែលមានទាំងអស់ និងមជ្ឈមណ្ឌលទូរស័ព្ទ សាធារណៈ និងប័ណ្ណស័ព្ទ

-សហការ ការងារបច្ចេកទេសជាមួយប្រតិបត្តិករទូរស័ព្ទជាដៃគូ ជាមួយក្រសួងបណ្តាទូរគមនាគមន៍ខេត្ត-ក្រុង និងនាយកដ្ឋានចំណុះក្រសួង

-កសាងគំរោងផែនការអភិវឌ្ឍន៍បណ្តាញនៅទីក្រុង និងជនបទតាមផែនការមេ

-គ្រប់គ្រង និងជួសជុលបណ្តាញទូរស័ព្ទ បណ្តាញបញ្ជូនស៊ីញ៉ាល់តាមកាប្លិ៍អុបទិក

-កសាងគំរោងចំណូលចំណាយ នៃការធ្វើអាជីវកម្ម លើវិស័យទូរគមនាគមន៍

-សហការសិក្សារៀបចំគំរោងអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ជាមួយប្រទេសផ្តល់ជំនួយ

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

ជំពូកទី ៤

អវសានប្បញ្ញត្តិ

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តន៍តាមខ្លឹមសារ នៃអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

un

មាត្រា ១១ : អនុក្រឹត្យនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់គ្រឹស្ថានសាធារណៈ លើវិស័យទូរគមនាគមន៍ កម្ពុជា និង ប្រៃសណីយ៍ កម្ពុជា ត្រូវបានបង្កើតឡើង ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សូរ ឃុន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

" ដើម្បីជូនជ្រាប "

- ដូចមាត្រា ១០ " ដើម្បីអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រចនាសម្ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃ ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

សំរេច

មាត្រា ១.-

ត្រូវបានបង្កើតអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ហៅកាត់ថា អ.ស.អ អនុលោមតាមមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។

មាត្រា ២.-

តួនាទី និងភារកិច្ចរបស់ អ.ស.អ មានជាអាទិ៍ដូចតទៅ :

- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- លើកសំណើជូនក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពិនិត្យ និងសំរេច នូវទស្សនទាន កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ យុទ្ធសាស្ត្រ គំរោងផែនការ ព្រមទាំងកម្មវិធីការងារសំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃទស្សនទាននោះ
- តាមដានអនុវត្តកម្មវិធីយុទ្ធសាស្ត្រ និង ផែនការសកម្មភាពកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ហើយរាយការណ៍ពីលទ្ធផលទទួលបានជូនក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំការប្រជុំនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌អោយបានជាប្រចាំ
- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដែលពាក់ព័ន្ធ នឹងកិច្ចការកែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធ្វើការសំរបសំរួលជាមួយអង្គការជាតិ និងអន្តរជាតិ និងតំណាងប្រទេសផ្តល់ជំនួយ ដើម្បីជំរុញប្រតិបត្តិការដៃគូអោយបានរឹងមាំ
- ផ្តល់ជូន ក្រសួង ស្ថាប័នរដ្ឋ តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន នូវបង្វែកបច្ចេកទេសចាំបាច់
- លើកសំណើតែងតាំង តាមករណីចាំបាច់ នូវអ្នកជំនាញការជាតិ អន្តរជាតិ និងឥស្សរជន ឬមន្ត្រីជាន់ខ្ពស់ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ចជាទីប្រឹក្សា ឬជំនួយការ ដើម្បីសិក្សាវិភាគលើគំរោងយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនានា លើវិស័យកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជន ដែលមានគុណសម្បត្តិមកចូលរួមប្រជុំពិគ្រោះយោបល់
- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- អនុវត្តរាល់ភារកិច្ច ដែលសហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ប្រគល់ឱ្យ ។

មាត្រា ៣.-

ភារកិច្ច និងបេសកកម្មពាក់ព័ន្ធកំណែទំរង់ច្បាប់មានជាអាទិ៍ដូចតទៅ :

- ពង្រឹងសមត្ថភាព កសាងច្បាប់ នៅតាមស្ថាប័នរដ្ឋ
- រៀបចំនីតិវិធីនៃការព្រាងច្បាប់អោយមានប្រសិទ្ធិភាព
- តាមដាន និងជំរុញការងារកសាងច្បាប់ អោយស្របទៅតាមនីតិវិធីជាធរមាន

- សំរបសំរួលការផ្តួចផ្តើមកសាងច្បាប់រវាង ក្រសួង ស្ថាប័ន អង្គភាព និងអង្គការអន្តរជាតិដទៃទៀត
- រៀបចំសន្ទានុក្រម និងវចនានុក្រម វាក្យស័ព្ទពាក្យពេចន៍ និងប្រជុំពាក្យផ្នែកច្បាប់ ដើម្បីសំរួលដល់ការងារព្រាងច្បាប់
- ជំរុញអោយមានការផ្សព្វផ្សាយច្បាប់ និងបទបញ្ញាទាំងឡាយអោយកាន់តែប្រសើរឡើង ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីពន្យល់ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ
- រៀបចំកម្មវិធី និងបង្កើតយន្តការការពារសិទ្ធិជាមូលដ្ឋាន របស់ប្រជាពលរដ្ឋអោយបានកាន់តែប្រសើរឡើង ។

មាត្រា ៤.-

ភារកិច្ច និងបេសកកម្មទាក់ទងនឹងកំណែទំរង់ប្រព័ន្ធយុត្តិធម៌មានជាអាទិ៍ដូចតទៅ :

- រៀបចំកម្មវិធីពង្រឹងសេវាយុត្តិធម៌ ដោយជំរុញអោយមានឯករាជ្យភាព ការជឿទុកចិត្ត មានតម្លាភាព និងការទទួលខុសត្រូវខ្ពស់របស់ចៅក្រម
- រៀបចំកម្មវិធីបង្កើនគុណភាពនៃសេវាប្រព័ន្ធយុត្តិធម៌ តាមរយៈការផ្តល់ជំនួយសេវាផ្នែកច្បាប់អោយមានគុណភាពខ្ពស់ ការបង្កើនចំនួនមេធាវី ការផ្តល់ការអប់រំ និងបណ្តុះបណ្តាល អោយមានប្រសិទ្ធិភាពខ្ពស់
- រៀបចំកម្មវិធី ដើម្បីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសំរាប់អនុវត្តសេចក្តីសំរេចរបស់តុលាការ
- ជំរុញអោយមានមូលដ្ឋានទិន្នន័យនៃសេចក្តីសំរេចរបស់តុលាការពីមុនៗមក
- រៀបចំនីតិវិធីនិងយន្តការដោះស្រាយជម្លោះ ដើម្បីជំនួសការកាត់សេចក្តីសាមញ្ញ ដោយបង្កើតអោយមានមជ្ឈត្តកម្មពាណិជ្ជកម្ម និងយន្តការសំរាប់ដោះស្រាយវិវាទតូចតាចតាមរយៈការសំរុះសំរួល ។

មាត្រា ៥.-

អង្គភាពសំរបសំរួលអចិន្ត្រៃយ៍នេះមានសមាសភាពដូចតទៅ :

១- ឯកឧត្តម	**ស៊ុំ ម៉ានិត**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌	ប្រធាន
២- ឯកឧត្តម	**អ៊ុង វឌ្ឍនា**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	អនុប្រធាន
៣- ឯកឧត្តម	**សុខ ចិន្តា**	អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក

៤- ឯកឧត្តម **សំ សុខផល**	អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៥- ឯកឧត្តម **ទី តាយី**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦- ឯកឧត្តម **វឿល មួន**	សមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម	សមាជិក
៧- ឯកឧត្តម **ក្រាញ់ ជ័យលាភីតូនី**	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
៨- ឯកឧត្តម **ម៉ៅ ថូរ៉ា**	អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម	សមាជិក
៩- បណ្ឌិត **ឆិញ ច័ន្ទវិបុល**	តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា	សមាជិក

មាត្រា ៦.-

អ.ស.អ ត្រូវធ្វើការប្រជុំ តាមការអញ្ជើញរបស់ប្រធានអង្គភាព យ៉ាងតិចឱ្យបានម្តងក្នុងមួយខែ ។

មាត្រា ៧.-

អ.ស.អ ត្រូវមានអង្គភាពគ្រប់គ្រងគំរោងមួយ ដើម្បីជាជំនួយដល់ប្រធាន អ.ស.អ ក្នុងកិច្ចការរដ្ឋបាលទូទៅ និងកិច្ចការហិរញ្ញវត្ថុរបស់គំរោងនៃការកែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។ អង្គភាពនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញភារកិច្ចនិងបេសកកម្មរបស់ខ្លួន ។

មាត្រា ៨.-

អ.ស.អ អាចបង្កើត និងអាចពង្រីករចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួន ទៅតាមទំហំការងារជាក់ស្តែង ដើម្បីអនុវត្តយុទ្ធសាស្ត្រ គំរោងអោយមានប្រសិទ្ធិភាព ។

មាត្រា ៩.-

អ.ស.អ មានសិទ្ធិទទួលប្រាក់អំណោយ និងកិច្ចឧបត្ថម្ភផ្សេងៗផ្ទាល់ពីប្រទេស ស្ថាប័ន ឬអង្គការអន្តរជាតិនានា ។

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ស្ថាប័នដែលពាក់ព័ន្ធ និង ប្រធានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៥ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីសុំហត្ថលេខា"

សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឌិត មន្ទី **សុខ អាន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ភារកិច្ច និង បេសកកម្មរបស់ក្រុមប្រឹក្សា កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៩៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

សំរេច

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។

មាត្រា ២.-

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌មានភារកិច្ច និងបេសកកម្មដូចតទៅ :

១- លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវទស្សនទាននៃកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និងយុទ្ធសាស្ត្រ គំរោងផែនការ ព្រមទាំងកម្មវិធីការងារ សំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃទស្សនទាននោះ

២- អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការនូវយុទ្ធសាស្ត្រ និងកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

៣- អនុម័តវិធានការចាំបាច់ទាំងឡាយ ក្នុងការដាក់អោយដំណើរការកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៤- ចេញសេចក្តីសំរេច និង សេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដើម្បីដឹកនាំ និងជំរុញដំណើរការកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៥- សំរបសំរួលបណ្តាសកម្មភាពរបស់ក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

៦- តាមដានការអនុវត្តកម្មវិធីកំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួង ស្ថាប័នយុត្តិធម៌ ស្ថាប័ននានា និងរាយការណ៍ពីលទ្ធផលទទួលបាន ព្រមទាំងសំណូមពរពាក់ព័ន្ធនានា ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

៧- ទំនាក់ទំនង សំរបសំរួល ដើម្បីកេណ្ឌធនធានពីរដ្ឋ និងជំនួយអន្តរជាតិចាំបាច់

៨- ជំរុញ ការងារផ្សព្វផ្សាយពត៌មាន ស្តីពីសកម្មភាព និងសមិទ្ធផលនៃការងារកំណែទំរង់នេះ

៩- បង្កលក្ខណៈ និងរៀបចំអោយមានការចូលរួមផ្តល់យោបល់ពីអង្គការក្រៅរដ្ឋាភិបាល និងសង្គម ស៊ីវិល នានា

១០- អនុវត្តរាល់ភារកិច្ច ផ្សេងៗទៀត ដែលឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋប្រគល់អោយ ។

មាត្រា ៣.-

ក្នុងការបំពេញភារកិច្ច និងបេសកកម្មខាងលើនេះក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានសិទ្ធិប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៤.-

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានខ្ទង់ថវិកាដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៥.-

ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវបានផ្តត់ផ្គង់ដោយ :

- វិភាគទាននៃថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ស្ថាប័នដែលពាក់ព័ន្ធ និងសហប្រធាន ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី " ដើម្បីសុំហត្ថលេខា "

សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឌិត មន្ទី **សុខ អាន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ ស្តីពីការបង្កើតគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១:តែងតាំងលោក **ខណ្ណ សំណាង** ប្រធានការិយាល័យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ។

មាត្រា២:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ
-ដូចមាត្រា២
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤០៨...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚៚៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ស៊ីមិហ្សុ យ៉ូស៊ីតាកា** ដែលបានធ្វើអំណោយជាថវិកាចំនួន ៣០.៥៥៣ USD សំរាប់ជួយសាងសង់អគារសិក្សា ០១ ខ្នង នៅសាលា បឋមសិក្សាខ្ញុំត្បូង ក្នុងស្រុកពារាំង ខេត្តព្រៃវែង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិៗ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៤០៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚៚៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន " **ក្រុមអាស៊ីគីតា និង សមាគមបណ្តុះវប្បធម៌អន្តរជាតិ ក្រុមអាស៊ីគីតា** " នៅប្រទេសជប៉ុន ដែលបានផ្តល់ថវិកាចំនួន ២៩.៥៥៣ USD ជួយសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សា សែនសុខ ក្នុងខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤១០ អនក្រ.បក - ១៩

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **គីម៉ូរ៉ាក់ យ៉ាអិកុ** ជនជាតិជប៉ុន ដែលបានធ្វើអំណោយជាថវិកា ចំនួន ៣៤.៥២៣ USD សំរាប់ជួយសាងសង់អគារសិក្សា ០១ ខ្នង នៅសាលាបឋមសិក្សាអង្គលំទង ក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤១១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ**ចំនួន ០១គ្រឿង ជូនលោក **ឃួន កែន** និងលោកស្រី **ត្រាប យ៉ាន** ដែលបានបរិច្ចាគថវិកាចំនួន ១២.៥០០ ដុល្លារអាមេរិក ក្នុងការជួយកសាងព្រះវិហារវត្តពោធិឧត្តម ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្ត-ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៤១៧...អនក.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រ េ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងផ្លូវលំ ០២ ខ្សែ ប្រវែង ១៣.៧០០ម៉ែត្រ នៅក្នុងឃុំជ្រៃ និងឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ :

- លោក **ហេង ឆាត** ថវិកាចំនួន ៩៩.៩៨៨ ដុល្លារអាមេរិក

ខ_មេដាយសំរិទ្ធស្ថាបនាជាតិ :

- លោក **ខៀវ ម៉ឺង** ថវិកាចំនួន ៣.០០០ ដុល្លារអាមេរិក

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **នីវ៉ាណូ នីឈីកូ** (**Niwano Nichiko**) ប្រធានអង្គការពុទ្ធសាសនាជប៉ុន និកាយ រិស្សូកូសី - កៃ និង ជាប្រធានមូលនិធិ នីវ៉ាណូសន្តិភាព ដែលបានផ្តល់វិភាគទានយ៉ាងធំធេង ក្នុងការស្តារឡើងវិញនូវវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា ពិសេសបានផ្តល់ថវិកាបោះពុម្ពសៀវភៅធម៌ អក្សរ - សាស្ត្រទូទៅ សំរាប់វិស័យពុទ្ធិកសិក្សា និង បំរើសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទ ព្រមទាំងបានជួយសាងសង់អគារពុទ្ធសាសនបណ្ឌិត្យ បំពាក់សំភារៈការិយាល័យ គ្រឿងសង្ហារិមគ្រប់គ្រាន់ និងសំណង់ផ្សេងៗជាច្រើនទៀត ចំណាយអស់ថវិកាសរុបចំនួន ១.៦០២.៣១២ ដុល្លារអាមេរិក ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤១៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ០២ រូប រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកាជួយកសាងកុដិ ០១ ខ្នង សាលាពុទ្ធិកបឋមសិក្សា ០១ ខ្នង មាន ០២ បន្ទប់ ក្តារខៀន ០២ តុគ្រូ ០១ និង កៅអី ២០ នៅវត្តវេឡុវនារាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ចំនួន ២១.០០៦ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ÷

១- លោក **ស៊ឿម ផៀង**
២- លោកស្រី **យ៉េ សារ៉ន**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្ត - បន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៧ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍនការងារ** ជូនដល់អស់លោកមេភូមិចំនួន ៩៩២ រូប និងជំនួយការឃុំចំនួន ១២៩ រូប ក្នុងខេត្តកណ្តាល ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-	លោក ព្រាប អ៊ុល	មេភូមិ ក្បាលជ្រោយ	ឃុំកំពង់ភ្នំ	ស្រុកលើកដែក
២-	លោក ទេព អុន	មេភូមិ កំពង់ពោធិ	ឃុំកំពង់ភ្នំ	ស្រុកលើកដែក
៣-	លោក កេង ទ្រី	មេភូមិ អំពិលទឹក	ឃុំកំពង់ភ្នំ	ស្រុកលើកដែក
៤-	លោក សុខ អោ	មេភូមិ កោះចំរើន	ឃុំកំពង់ភ្នំ	ស្រុកលើកដែក
៥-	លោក ធឹក ហ៊ិន	មេភូមិ កំពង់ចំលង	ឃុំព្រែកទន្លាប់	ស្រុកលើកដែក
៦-	លោក រស់ រិន	មេភូមិ ស្ពានដែក	ឃុំព្រែកទន្លាប់	ស្រុកលើកដែក
៧-	លោក ព្រុំ ហេង	មេភូមិ ព្រែកបាក់	ឃុំព្រែកទន្លាប់	ស្រុកលើកដែក
៨-	លោក សុខ ឬ	មេភូមិ ព្រែកតូច	ឃុំព្រែកទន្លាប់	ស្រុកលើកដែក
៩-	លោក តុប ស៊ុំ	មេភូមិ ព្រែកតូច	ឃុំព្រែកដាច់	ស្រុកលើកដែក
១០-	លោក យី សារឹម	មេភូមិ ព្រែកដាច់	ឃុំព្រែកដាច់	ស្រុកលើកដែក
១១-	លោក អ៊ូ ជឹម	មេភូមិ តាហ៊ីង	ឃុំព្រែកដាច់	ស្រុកលើកដែក
១២-	លោក ភុំ សន	មេភូមិ កោះកន្ធាយ	ឃុំព្រែកដាច់	ស្រុកលើកដែក
១៣-	លោក មុំ ឈឺន	មេភូមិ ថ្មី	ឃុំពាមរាំង	ស្រុកលើកដែក
១៤-	លោក តាត់ ស៊ុន	មេភូមិ ពាមរាំងលើ	ឃុំពាមរាំង	ស្រុកលើកដែក

១៥-	លោក ស៊ឹម ត្រាវ	មេភូមិ ពាមរាំងក្រោម	ឃុំពាមរាំង	ស្រុកលើកដែក
១៦-	លោក អ៊ុន ប៊ិន	មេភូមិ បឹងលើ	ឃុំខ្ពបអាទាវ	ស្រុកលើកដែក
១៧-	លោក យិន យ៉ន	មេភូមិ បឹងកណ្ដាល	ឃុំខ្ពបអាទាវ	ស្រុកលើកដែក
១៨-	លោក ផន់ សារឿន	មេភូមិ បឹងក្រោម	ឃុំខ្ពបអាទាវ	ស្រុកលើកដែក
១៩-	លោក ហ៊ាន សួន	មេភូមិ ដងក្ដោង	ឃុំសណ្ដារ	ស្រុកលើកដែក
២០-	លោក ស៊ាង ស្រ៊ុន	មេភូមិ កណ្ដាល	ឃុំសណ្ដារ	ស្រុកលើកដែក
២១-	លោក សាន់ ឌិប	មេភូមិ ចុងកោះ	ឃុំសណ្ដារ	ស្រុកលើកដែក
២២-	លោក សន សុង	មេភូមិ រាំងផ្លូវ	ឃុំក្ដួមសំណរ	ស្រុកលើកដែក
២៣-	លោក ឡៅ ឡេង	មេភូមិ ក្ដួមសំណរលើ	ឃុំក្ដួមសំណរ	ស្រុកលើកដែក
២៤-	លោក គ្រី ឡឹម	មេភូមិ ក្ដួមសំណរក្រោម	ឃុំក្ដួមសំណរ	ស្រុកលើកដែក
២៥-	លោក ព្រុយ ពន	មេភូមិ ចុងកោះ	ឃុំកោះដាច់	ស្រុកមុខកំពូល
២៦-	លោក យ៉ាន់ សយ	មេភូមិ ល្វា	ឃុំកោះដាច់	ស្រុកមុខកំពូល
២៧-	លោក លន់ សេន	មេភូមិ ក្បាលកោះ	ឃុំកោះដាច់	ស្រុកមុខកំពូល
២៨-	លោក ជឹម ជិន	មេភូមិ កោះដាច់	ឃុំកោះដាច់	ស្រុកមុខកំពូល
២៩-	លោក ជិន ជន	មេភូមិ រនះ	ឃុំកោះដាច់	ស្រុកមុខកំពូល
៣០-	លោក ឡាច ឡែន	មេភូមិ បាក់ខែងលើ	ឃុំបាក់ខែង	ស្រុកមុខកំពូល
៣១-	លោក សេង ថុង	មេភូមិ ក្ដីចាស់	ឃុំបាក់ខែង	ស្រុកមុខកំពូល
៣២-	លោក បាន ប៉េងអាន	មេភូមិ ចំបក់មាស	ឃុំបាក់ខែង	ស្រុកមុខកំពូល
៣៣-	លោក ឡេង ប៊ុនលីម	មេភូមិ ព្រែកតាបែន	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៤-	លោក គាំ ញឹម	មេភូមិ ព្រែកថ្មី	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៥-	លោក ម៉ុក ឆាន	មេភូមិ ក្រោម	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៦-	លោក រស់ រឹម	មេភូមិ កណ្ដាល	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៧-	លោក ម៉ាន់ តែម	មេភូមិ លើ	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៨-	លោក ឆឹត ហាក់	មេភូមិ កោះរកា	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៣៩-	លោក សុខ រ៉េង	មេភូមិ ឈើទាល	ឃុំព្រែកអញ្ចាញ	ស្រុកមុខកំពូល
៤០-	លោក យិន លី	មេភូមិ ឫស្សីជ្រោយមេតីក្រោម	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤១-	លោក ភួប សាម្បេះ	មេភូមិ ជ្រោយមេត្រីលើ	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤២-	លោក ឡាយ ឈុន	មេភូមិ ព្រែកតាសោម	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤៣-	លោក ពុយ ហ៊ាង	មេភូមិ ឫស្សីជ្រោយ	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤៤-	លោក ស្វ ហ៊ាង	មេភូមិ បឹងជន្ទេន	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤៥-	លោក ញឹម ជឹម	មេភូមិ ព្រែកយាយហ៊ិនទី១	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤៦-	លោក សំ សុខន	មេភូមិ ព្រែកយាយហ៊ិនទី២	ឃុំឫស្សីជ្រោយ	ស្រុកមុខកំពូល
៤៧-	លោក អួន វួន	មេភូមិ សាមគ្គី	ឃុំព្រែកដំបង	ស្រុកមុខកំពូល
៤៨-	លោក គឹម ឆន	មេភូមិ វត្តថ្មី	ឃុំព្រែកដំបង	ស្រុកមុខកំពូល

៤៩-	លោក ញ៉ែម កន	មេភូមិ ឡូត៍ដូ	ឃុំព្រែកដំបង	ស្រុកមុខកំពូល
៥០-	លោក កែវ កែម	មេភូមិ ស្វាយជ្រុំ	ឃុំព្រែកដំបង	ស្រុកមុខកំពូល
៥១-	លោក ទុយ ប៊ុន	មេភូមិ រកាកោង	ឃុំរកាកោងទី១	ស្រុកមុខកំពូល
៥២-	លោក ឈិត សារិន	មេភូមិ ពាម	ឃុំរកាកោងទី១	ស្រុកមុខកំពូល
៥៣-	លោក ស៊ុំ សយ	មេភូមិ ព្រែកផ្ដៅ	ឃុំរកាកោងទី១	ស្រុកមុខកំពូល
៥៤-	លោក ម៉ែន សំអឿន	មេភូមិ គោហេ	ឃុំរកាកោងទី១	ស្រុកមុខកំពូល
៥៥-	លោក កុយ រុន	មេភូមិ ដើមជ្រៃ	ឃុំរកាកោងទី២	ស្រុកមុខកំពូល
៥៦-	លោក រត្ន សូត្រ	មេភូមិ ពោធិរលំ	ឃុំរកាកោងទី២	ស្រុកមុខកំពូល
៥៧-	លោក ពុធ ប៊ុន	មេភូមិ ស្ពានថ្មី	ឃុំរកាកោងទី២	ស្រុកមុខកំពូល
៥៨-	លោក ស៊្រុន ជាម	មេភូមិ ព្រែកជ្រៅ	ឃុំរកាកោងទី២	ស្រុកមុខកំពូល
៥៩-	លោក ជាម ស៊ុន	មេភូមិ ក្រងស្វាយ	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
៦០-	លោក ឱ ផ្លូវ	មេភូមិ កំពង់ប្រាសាទ	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
៦១-	លោក អ៊ូ ម៉ៅ	មេភូមិ ឈើទាលភ្លោះ	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
៦២-	លោក គង់ ឃឿន	មេភូមិ ស្វាយអំពារ	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
៦៣-	លោក ភូ ផែប	មេភូមិ ថ្មី	ឃុំស្វាយអំពារ	ស្រុកមុខកំពូល
៦៤-	លោក គោ ផាត	មេភូមិ អន្លង់ស្វែង	ឃុំសំបួរមាស	ស្រុកមុខកំពូល
៦៥-	លោក ផ្ទេក ឈន	មេភូមិ ជ្រៃ១០០	ឃុំសំបួរមាស	ស្រុកមុខកំពូល
៦៦-	លោក ប្រាជ្ញ ម៉ម	មេភូមិ អំពិលទឹក	ឃុំសំបួរមាស	ស្រុកមុខកំពូល
៦៧-	លោក អ៊ឹម អាន	មេភូមិ ពោង	ឃុំសំបួរមាស	ស្រុកមុខកំពូល
៦៨-	លោក ជ័យ ឆុន	មេភូមិ ព្រែកឬស្ស	ឃុំសំបួរមាស	ស្រុកមុខកំពូល
៦៩-	លោក មាច ហ៊ិល	មេភូមិ ក្រោលគោ	ឃុំសំបួរមាស	ស្រុកមុខកំពូល
៧០-	លោក ហាយ យុន	មេភូមិ ពាម	ឃុំសំបួរមាស	ស្រុកមុខកំពូល
៧១-	លោក ឯក សំណាង	មេភូមិ ដើមមៀន	ឃុំដើមមៀន	ស្រុកតាខ្មៅ
៧២-	លោក ហ៊ិន ឡាច	មេភូមិ ព្រែកតាពៅ	ឃុំដើមមៀន	ស្រុកតាខ្មៅ
៧៣-	លោក ជុក សារឿន	មេភូមិ ដើមគរ	ឃុំដើមមៀន	ស្រុកតាខ្មៅ
៧៤-	លោក សួន សាវុន	មេភូមិ ស្ទឹងជ្រៅ	ឃុំដើមមៀន	ស្រុកតាខ្មៅ
៧៥-	លោក យឹម សុខជា	មេភូមិ តាខ្មៅ	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
៧៦-	លោក គង់ សារឿន	មេភូមិ ថ្មី	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
៧៧-	លោក យឹម រ៉ុង	មេភូមិ ព្រែកសំរោង	ឃុំតាខ្មៅ	ស្រុកតាខ្មៅ
៧៨-	លោក សាន តុង	មេភូមិ ក្រពើហា	ឃុំព្រែកឬស្សី	ស្រុកតាខ្មៅ
៧៩-	លោក លឹម រឿន	មេភូមិ ព្រែកអញ្ចាញ	ឃុំព្រែកឬស្សី	ស្រុកតាខ្មៅ
៨០-	លោក ស៊ឹម កន	មេភូមិ ព្រែកឬស្សី	ឃុំព្រែកឬស្សី	ស្រុកតាខ្មៅ
៨១-	លោកស្រី ប៊ុន ខ្ទឹមចាន់	មេភូមិ ព្រែកកាត់	ឃុំតាក្ដុល	ស្រុកតាខ្មៅ
៨២-	លោក ផេង ផាន	មេភូមិ ព្រែកឡុង	ឃុំតាក្ដុល	ស្រុកតាខ្មៅ

៨៣-	លោក ចាប ឃឹម	មេភូមិ តាក្តុល	ឃុំតាក្តុល	ស្រុកតាខ្មៅ
៨៤-	លោក យ៉ង ហឿង	មេភូមិ ព្រែកហូរលិច	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៨៥-	លោក ផន ចឹម	មេភូមិ ព្រែកហូរកើត	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៨៦-	លោក ទុយ សាន	មេភូមិ បក្តាជី	ឃុំព្រែកហូរ	ស្រុកតាខ្មៅ
៨៧-	លោក អ៊ឹម អេម	មេភូមិ កំពង់សំណាញ់	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៨៨-	លោក ព្រឹង សែម	មេភូមិ ខ្ពបវែង	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៨៩-	លោក ទៀង ដាំ	មេភូមិ ព្រែករាំង	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៩០-	លោក ទូក ហៃ	មេភូមិ ក្រពៅ	ឃុំកំពង់សំណាញ់	ស្រុកតាខ្មៅ
៩១-	លោក ប៊ុង ភួង	មេភូមិ ក្បាលកោះធំ	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩២-	លោក នៅ ងួន	មេភូមិ កណ្តាលកោះធំ	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩៣-	លោក គឹម ផុន	មេភូមិ ចុងកោះធំ	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩៤-	លោក ឆែម នី	មេភូមិ ក្បាលកោះថ្មី	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩៥-	លោក ត្រឹង សំអឿន	មេភូមិ ចុងកោះថ្មី	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩៦-	លោក តា ឈួ	មេភូមិ ពោធិទន្ទេ	ឃុំកោះធំ(ក)	ស្រុកកោះធំ
៩៧-	លោក ញឹក ម៉ូយ	មេភូមិ សំប៉ាន	ឃុំកោះធំ(ខ)	ស្រុកកោះធំ
៩៨-	លោក សៅ គុន	មេភូមិ ព្រែកតាកេរ	ឃុំកោះធំ(ខ)	ស្រុកកោះធំ
៩៩-	លោក ឈាង ស៊្រុន	មេភូមិ ព្រែកសំរោង	ឃុំកោះធំ(ខ)	ស្រុកកោះធំ
១០០-	លោក ហ៊ី សុង	មេភូមិ ព្រែកបិ	ឃុំកោះធំ(ខ)	ស្រុកកោះធំ
១០១-	លោក ឡេង ក្រាម	មេភូមិ ស្វាយតាមេឃ	ឃុំកោះធំ(ខ)	ស្រុកកោះធំ
១០២-	លោក ថាន់ គ្រុយ	មេភូមិ ព្រែកតាដួង	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៣-	លោក ឡោ ឡេង	មេភូមិ ព្រែកយាយហាយ	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៤-	លោក កែន ឡេង	មេភូមិ សំបួរលើ	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៥-	លោក ខិក ហោ	មេភូមិ សំបួរក្រោម	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៦-	លោក ឃិន ស៊្រុន	មេភូមិ ស្វាយលើ	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៧-	លោក ហោ ស៊ា	មេភូមិ ស្វាយកណ្តាល	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៨-	លោក អែម ផុន	មេភូមិ ស្វាយក្រោម	ឃុំព្រែកថ្មី	ស្រុកកោះធំ
១០៩-	លោក អ៊ុត អៀង	មេភូមិ ព្រែកថ្មី	ឃុំព្រែកថ្មី	ស្រុកកោះធំ
១១០-	លោក ម៉ាត់ លាស់	មេភូមិ ចាមលើ	ឃុំព្រែកថ្មី	ស្រុកកោះធំ
១១១-	លោក ឈិន ឆាង	មេភូមិ ព្រែកតាហ៊ីង	ឃុំព្រែកថ្មី	ស្រុកកោះធំ
១១២-	លោក ស្រេង ប៉េងលន់	មេភូមិ ព្រែកធន់	ឃុំព្រែកថ្មី	ស្រុកកោះធំ
១១៣-	លោក សុះ ម៉េត	មេភូមិ ចាមក្រោម	ឃុំព្រែកថ្មី	ស្រុកកោះធំ
១១៤-	លោក វ៉ៃ ប៊ុនហេង	មេភូមិ ព្រែកមេស្រុក	ឃុំព្រែកស្តី	ស្រុកកោះធំ
១១៥-	លោក ជា ថាន់	មេភូមិ ព្រែកលោក	ឃុំព្រែកស្តី	ស្រុកកោះធំ
១១៦-	លោក ឈិន វ៉ៃ	មេភូមិ ព្រែកប៉ុក	ឃុំព្រែកស្តី	ស្រុកកោះធំ

១១៧-	លោក គីម ផល្លី	មេភូមិ ចុងព្រែក	ឃុំព្រែកស្តី	ស្រុកកោះធំ
១១៨-	លោក គន ងន	មេភូមិ អន្លង់សាន	ឃុំព្រែកស្តី	ស្រុកកោះធំ
១១៩-	លោក ឈឹម អ៊ិត	មេភូមិ ព្រែកតាមេម	ឃុំព្រែកស្តី	ស្រុកកោះធំ
១២០-	លោក មឿ ណយ	មេភូមិ កោះចាស់	ឃុំព្រែកស្តី	ស្រុកកោះធំ
១២១-	លោក ថាន់ មាង	មេភូមិ ពោធិរាម្នា	ឃុំព្រែកស្តី	ស្រុកកោះធំ
១២២-	លោក យុង ហៃ	មេភូមិ ប្រធាតុ	ឃុំព្រែកស្តី	ស្រុកកោះធំ
១២៣-	លោក រស់ អ៊ឹម	មេភូមិ ក្បាលកោះទៀវ	ឃុំសំពៅពូន	ស្រុកកោះធំ
១២៤-	លោក ប៊ុម គុយ	មេភូមិ កោះទៀវ(ក)	ឃុំសំពៅពូន	ស្រុកកោះធំ
១២៥-	លោក ហែម ឈុន	មេភូមិ កោះទៀវ(ខ)	ឃុំសំពៅពូន	ស្រុកកោះធំ
១២៦-	លោក ឈឹម ឈិន	មេភូមិ ខ្ពប	ឃុំសំពៅពូន	ស្រុកកោះធំ
១២៧-	លោក ចាន់ នី	មេភូមិ កំពង់ថ្កុល	ឃុំសំពៅពូន	ស្រុកកោះធំ
១២៨-	លោក ស្រី សុផល	មេភូមិ កញ៉ាល់គឿង	ឃុំសំពៅពូន	ស្រុកកោះធំ
១២៩-	លោក ស៊ុន ស៊ន	មេភូមិ ព្រែកស៊ឹង	ឃុំសំពៅពូន	ស្រុកកោះធំ
១៣០-	លោក ស្រ៊ន ស្រ៊ុន	មេភូមិ ជ្រៃធំ	ឃុំសំពៅពូន	ស្រុកកោះធំ
១៣១-	លោក សា តឹយ	មេភូមិ ព្រែកស្បូវ	ឃុំសំពៅពូន	ស្រុកកោះធំ
១៣២-	លោក ឯក ថា	មេភូមិ ព្រែកម្រិញ	ឃុំពោធិបាន	ស្រុកកោះធំ
១៣៣-	លោក ផៃ ផា	មេភូមិ ខ្វែងអណ្តូង	ឃុំពោធិបាន	ស្រុកកោះធំ
១៣៤-	លោក ម៉ៅ ជិនហេង	មេភូមិ ក្បាលជ្រោយ	ឃុំពោធិបាន	ស្រុកកោះធំ
១៣៥-	លោក នៅ សេងហ៊ត	មេភូមិ ភូមិថ្មី	ឃុំពោធិបាន	ស្រុកកោះធំ
